# ឈ្មោះបច្ចេកទេសរបស់ផលិតផល៖ ធានារ៉ាប់រងធនលាភអប់រំសម្រាប់កុមារ និងការលោះបង់នូវបុព្វលាភធានារ៉ាប់រងសម្រាប់គ្រោះថ្នាក់បាត់បង់ជីវិតដោយយថាហេតុរបស់អ្នកស្នើសុំធានារ៉ាប់រង ខ និងលក្ខខណ្ឌសម្រាប់ "គម្រោងអនាគតភ្លឺសង្ឃឹមបុត្រធីតា" ផលិតផលទី៣របស់ ក្រុមហ៊ុនហ្គ្រេន ឆាយណា ឡាយហ្វ៍ អ៊ិនសួរេន ម.ក

## 1. សមាសភាពនៃកិច្ចសន្យាធានារ៉ាប់រង

កិច្ចសន្យាធានារ៉ាប់រង "គម្រោងអនាគតភ្លឺសង្ឃឹមបុត្រធីតា" (តទៅហៅថា "កិច្ចសន្យាធានារ៉ាប់រង") ត្រូវបានបង្កើតឡើងដោយវិញ្ញាបនបត្រធានារ៉ាប់រង ខ និងលក្ខខណ្ឌធានារ៉ាប់រង ពាក្យស្នើសុំធានារ៉ាប់រង (រួមមាន" លិខិតបញ្ជាក់ការស្នើសុំធានារ៉ាប់រងតាមរយៈអេឡិចត្រូនិច") របាយការណ៍ស្តីពីសុខភាព សៀវភៅផែនការធានារ៉ាប់រង និងឯកសារផ្សេងទៀតដែលទាក់ទងនឹងកិច្ចសន្យាធានារ៉ាប់រងនេះ។

## 2. ការបង្កើត និងសុពលភាពចូលជាធរមាននៃកិច្ចសន្យាធានារ៉ាប់រង

នៅពេលអ្នកស្នើសុំធានារ៉ាប់រងដាក់ពាក្យស្នើសុំ និងបានបំពេញបែបបទស្នើសុំធានារ៉ាប់រង ហើយក្រោយពេលក្រុមហ៊ុនយល់ព្រមធានា និងបានផ្តល់ដំណឹងដល់អ្នកស្នើសុំឱ្យបង់បុព្វលាភ កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបានបង្កើត។

ក្រោយពេលកិច្ចសន្យាធានារ៉ាប់រងត្រូវបានបង្កើត បន្ទាប់ពីអ្នកស្នើសុំធានារ៉ាប់រងបានបង់បុព្វលាភធានារ៉ាប់រងដំបូងទាំងអស់ កិច្ចសន្យាធានារ៉ាប់រងនឹងមានអនុភាព ហើយកាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យានេះត្រូវបានបញ្ជាក់ច្បាស់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ នៅពេលកិច្ចសន្យានេះមានអនុភាព ក្រុមហ៊ុននឹងចេញបណ្ណសន្យារ៉ាប់រងជូនអ្នកស្នើសុំភ្លាម។

## 3. លក្ខខណ្ឌតម្រូវផ្សេងៗដើម្បីដាក់ពាក្យស្នើសុំធានារ៉ាប់រង

អ្នកស្នើសុំធានារ៉ាប់រងត្រូវតែមានអាយុគ្រប់១៨ឆ្នាំ មិនមានជំងឺសតិអារម្មណ៍ ព្រមទាំងមានលទ្ធភាពបង់បុព្វលាភធានារ៉ាប់រងដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រង។

អ្នកស្នើសុំធានារ៉ាប់រង អាចដាក់ពាក្យស្នើសុំធានារ៉ាប់រងសម្រាប់កូនរបស់គាត់ ចៅៗរបស់គាត់ កុមារដទៃទៀតដែលជាសាច់ញាតិ ឬញាតិសន្តានរបស់គាត់ និងកុមារដែលត្រូវបានទទួលស្គាល់ដោយច្បាប់ថាស្ថិតនៅក្រោមការមើលថែរបស់គាត់។ បុគ្គលដែលបានរៀបរាប់ដូចខាងលើគឺជាអ្នកត្រូវបានធានារ៉ាប់រង។

អ្នកត្រូវបានធានារ៉ាប់រងត្រូវតែមានអាយុយ៉ាងតិច ៣០ថ្ងៃ និងមានអាយុក្រោម ១៥ឆ្នាំ។

កិច្ចសន្យាធានារ៉ាប់រងអាចត្រូវបានទិញមួយ ឬច្រើនច្បាប់។

## 4. រយៈពេលសម្រេចចិត្ត

គិតចាប់ពីថ្ងៃបន្ទាប់ដែលអ្នកស្នើសុំធានារ៉ាប់រងចុះហត្ថលេខាទទួលកិច្ចសន្យាធានារ៉ាប់រង អ្នកស្នើសុំធានារ៉ាប់រងមានពេល ២១ថ្ងៃ ដើម្បីសម្រេចចិត្ត។ នៅក្នុងអំឡុងពេលនេះ ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងសម្រេចចិត្តមិនទិញធានារ៉ាប់រងនេះទេ អ្នកស្នើសុំធានារ៉ាប់រងអាចស្នើសុំបញ្ចប់កិច្ចសន្យានៅក្នុងអំឡុងពេលនេះ។

កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់ គិតចាប់ពីពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានទទួលពាក្យស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ហើយក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចធានារ៉ាប់រងទៀតទេ ក្រុមហ៊ុននឹងទូទាត់បុព្វលាភ(ដោយគ្មានការប្រាក់) ជូនអ្នកស្នើសុំធានារ៉ាប់រងវិញ ប៉ុន្តែអ្នកស្នើសុំធានារ៉ាប់រងត្រូវបង់ប្រាក់ចំនួន ១០ ដុល្លារអាមេរិកទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងសម្រាប់ថ្លៃសេវាកម្ម។

## 5. រយៈពេលបង់បុព្វលាភ និងបុព្វលាភធានារ៉ាប់រង

រយៈពេលបង់បុព្វលាភដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះមាន២របៀបដូចជាការបង់រយៈពេល៣ឆ្នាំ និងការបង់រយៈពេល៦ឆ្នាំ។ នៅពេលដាក់ពាក្យស្នើសុំ អ្នកស្នើសុំអាចធ្វើការជ្រើសរើសរបៀបណាមួយជារយៈពេលបង់បុព្វលាភដែលបានព្រមព្រៀងគ្នា។ វិធីសាស្ត្របង់បុព្វលាភមានបួនរបៀប គឺការបង់ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស និងការបង់ប្រចាំខែ។ ហើយវិធីសាស្ត្រណាមួយ ដែលត្រូវបានជ្រើសរើសដោយអ្នកស្នើសុំធានារ៉ាប់រង គឺជារបៀបទូទាត់ប្រាក់ដែលបានព្រមព្រៀងគ្នា។

ចំនួនបុព្វលាភដែលត្រូវបង់សម្រាប់ការធានារ៉ាប់រងនេះត្រូវផ្អែកលើចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធ ១ 《តារាងអត្រាបុព្វលាភសម្រាប់គម្រោងអនាគតភ្លឺសង្ឃឹមបុត្រធីតាក្នុងមួយច្បាប់》 នៃ កិច្ចសន្យាធានារ៉ាប់រង។



អាគារកាណាឌីយ៉ាជាន់ទី26 CDEF វិថីព្រះអង្គឌួងលេខ315 ក្រុងភ្នំពេញ 26th Floor CDEF Canadia Tower 315 Ang Doung Street Phnom Penh Tel: 023989218

រយៈពេលបង់បុព្វលាភ វិធីសាស្ត្របង់បុព្វលាភ និងចំនួនទឹកប្រាក់រាល់ការបង់នីមួយៗត្រូវបានបញ្ជាក់ច្បាស់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង។

## 6. កាលបរិច្ឆេទបង់បុព្វលាភដំណាក់កាលបន្ទាប់ និងរយៈពេលអនុគ្រោះសម្រាប់ការបង់បុព្វលាភ

ក្នុងអំឡុងពេលទូទាត់បុព្វលាភដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រង កាលបរិច្ឆេទដែលបានព្រមព្រៀងគ្នាសម្រាប់ទូទាត់បុព្វលាភ គឺជាថ្ងៃបន្ទាប់នៃរាល់ខួបប្រចាំឆ្នាំ ថ្ងៃបន្ទាប់នៃរាល់ខួបប្រចាំឆមាស ថ្ងៃបន្ទាប់នៃរាល់ខួបប្រចាំត្រីមាស និងថ្ងៃបន្ទាប់នៃរាល់ខួបប្រចាំខែរបស់បណ្ណសន្យារ៉ាប់រង។ អ្នកស្នើសុំធានារ៉ាប់រងត្រូវបង់នូវបុព្វលាភដំណាក់កាលបន្ទាប់នៅថ្ងៃដែលបានព្រមព្រៀងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។

កិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានព្រមព្រៀងចែងនូវរយៈពេលអនុគ្រោះសម្រាប់បង់បុព្វលាភ។ រយៈពេលអនុគ្រោះដែលបានព្រមព្រៀងគ្នា គឺមានរយៈពេល៦០ថ្ងៃ ហើយត្រូវគណនាគិតចាប់ពីថ្ងៃបន្ទាប់នៃកាលបរិច្ឆេទបង់បុព្វលាភដែលបានបញ្ជាក់ខាងលើ។

ក្រុមហ៊ុនធានារ៉ាប់រងនឹងនៅតែមានទំនួលខុសត្រូវទៅលើវិសាលភាពនៃការធានាដដែលនៅក្នុងអំឡុងពេលនៃការអនុគ្រោះនេះ។ ប៉ុន្តែប្រសិនបើអ្នកដាក់ពាក្យស្នើសុំខកខានមិនបានទូទាត់ ឬសងបុព្វលាភធានារ៉ាប់រងនៅក្នុងអំឡុងពេលនៃការអនុគ្រោះនេះ កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវផ្អាកនៅថ្ងៃផុតកំណត់រយៈពេលអនុគ្រោះនេះ ហើយក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានទំនួលខុសត្រូវទៅលើវិសាលភាពនៃការធានានៅក្នុងអំឡុងពេលផ្អាកនោះទេ។

## 7. រយៈពេលធានារ៉ាប់រង

រយៈពេលធានារ៉ាប់រង ដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងត្រូវចាប់ផ្តើមពីកាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងរហូតដល់ខួបប្រចាំឆ្នាំរបស់បណ្ណសន្យារ៉ាប់រងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ២២ឆ្នាំ។ រយៈពេលធានារ៉ាប់រងនេះ ត្រូវបញ្ជាក់ឲ្យបានច្បាស់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង។

## 8. វិសាលភាពនៃការធានា

ក្នុងអំឡុងពេលនៃការធានារ៉ាប់រងដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុនធានារ៉ាប់រងនឹងធានាទៅតាមការព្រមព្រៀងដូចខាងក្រោម ÷

### 1. ការលើកលែងបុព្វលាភធានារ៉ាប់រង

ក្នុងអំឡុងពេលបង់បុព្វលាភធានារ៉ាប់រង ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងស្លាប់បាត់បង់ជីវិតដោយសារគ្រោះថ្នាក់ជាយថាហេតុ ក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមលើកលែងនូវបុព្វលាភធានារ៉ាប់រងលើកក្រោយៗទៀតដែលនឹងត្រូវបង់នៅក្នុងកិច្ចសន្យាធានារ៉ាប់រង ប៉ុន្តែចំពោះបុព្វលាភធានារ៉ាប់រងដែលបានបង់រួចមុនពេលអ្នកស្នើសុំធានារ៉ាប់រងស្លាប់បាត់បង់ជីវិត បុព្វលាភនោះមិនអាចប្រគល់ជូនវិញបានទេ។

### 2. អត្ថប្រយោជន៍សម្រាប់ការអប់រំ

នៅពេលដាក់ពាក្យស្នើសុំធានារ៉ាប់រង អ្នកស្នើសុំត្រូវជ្រើសរើសនូវវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រទាំង៣របៀប A, B, C ដូចខាងក្រោមដើម្បីទទួលអត្ថប្រយោជន៍÷

វិធីសាស្ត្រ A: (ទទួលអត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់បឋមសិក្សា ថ្នាក់វិទ្យាល័យ និងថ្នាក់ឧត្តមសិក្សា)

ក្រោយពេលដែលរយៈពេលបង់បុព្វលាភត្រូវបានបញ្ចប់ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ចាប់ពីអាយុ៧ឆ្នាំដល់អាយុក្រោម១៣ឆ្នាំ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់បឋមសិក្សាចំនួន ៣០០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយច្បាប់នៅរៀងរាល់ខួបនៃបណ្ណសន្យារ៉ាប់រងនីមួយៗ។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ចាប់ពីអាយុ១៣ឆ្នាំដល់អាយុក្រោម១៩ឆ្នាំ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់វិទ្យាល័យចំនួន ៤០០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយច្បាប់នៅរៀងរាល់ខួបនៃបណ្ណសន្យារ៉ាប់រងនីមួយៗ។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ចាប់ពីអាយុ១៩ឆ្នាំដល់ថ្ងៃផុតកំណត់នៃរយៈពេលធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់ឧត្តមសិក្សាចំនួន ៥០០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយច្បាប់នៅរៀងរាល់ខួបនៃបណ្ណសន្យារ៉ាប់រងនីមួយៗ។

វិធីសាស្ត្រ B: (ទទួលអត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់វិទ្យាល័យ និងថ្នាក់ឧត្តមសិក្សា)

ក្រោយពេលដែលរយៈពេលបង់បុព្វលាភត្រូវបានបញ្ចប់ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ចាប់ពីអាយុ១៣ឆ្នាំដល់អាយុក្រោម១៩ឆ្នាំ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់វិទ្យាល័យចំនួន ៥០០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយច្បាប់នៅរៀងរាល់ខួបនៃបណ្ណសន្យារ៉ាប់រងនីមួយៗ។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ចាប់ពីអាយុ១៩ឆ្នាំដល់ថ្ងៃផុតកំណត់នៃរយៈពេលធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់ឧត្តមសិក្សាចំនួន ៧០០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយច្បាប់នៅរៀងរាល់ខួបនៃបណ្ណសន្យារ៉ាប់រងនីមួយៗ។

វិធីសាស្ត្រ C: (ទទួលអត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់ឧត្តមសិក្សា)

ក្រោយពេលដែលរយៈពេលបង់បុព្វលាភត្រូវបានបញ្ចប់ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ចាប់ពីអាយុ១៩ឆ្នាំដល់ថ្ងៃផុតកំណត់នៃរយៈពេលធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់ឧត្តមសិក្សាចំនួន ១២០០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយច្បាប់នៅរៀងរាល់ខួបនៃបណ្ណសន្យារ៉ាប់រងនីមួយៗ។

បញ្ជាក់÷ ប្រសិនបើរយៈពេលព្រមព្រៀមបង់បុព្វលាភមានរយៈពេល៣ឆ្នាំ រាល់ឃ្លា "ក្រោយពេលដែលរយៈពេលបង់បុព្វលាភត្រូវបានបញ្ចប់ "ដែលបានរៀបរាប់ខាងលើមានន័យថានៅពេលដែលកិច្ចសន្យានេះគ្រប់គម្រប់ខួប៣ឆ្នាំ។ ប៉ុន្តែប្រសិនបើរយៈពេលព្រមព្រៀមបង់បុព្វលាភមានរយៈពេល៦ឆ្នាំ រាល់ឃ្លា "ក្រោយពេលដែលរយៈពេលបង់បុព្វលាភត្រូវបានបញ្ចប់ "ដែលបានរៀបរាប់ខាងលើមានន័យថានៅពេលដែលកិច្ចសន្យានេះគ្រប់គម្រប់ខួប៦ឆ្នាំ។

3. **អត្ថប្រយោជន៍នៅពេលស្លាប់បាត់បង់ជីវិត**

ចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងរហូតដល់ កាលបរិច្ឆេទផុតកំណត់នៃរយៈពេលធានារ៉ាប់រង ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ហើយមិនធ្លាប់មានសំណងធានារ៉ាប់រងណាមួយត្រូវបានទទួលមុនហេតុការណ៍នោះ ក្រុមហ៊ុនធានារ៉ាប់រងនឹងប្រគល់ត្រឡប់នូវបុព្វលាភដែលអ្នកស្នើសុំបានបង់ដោយមិនមានការប្រាក់ទៅឲ្យអ្នកស្នើសុំធានារ៉ាប់រងវិញ ហើយកិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់។

ចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងរហូតដល់កាលបរិច្ឆេទផុតកំណត់នៃរយៈពេលធានារ៉ាប់រង ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ហើយចំនួនសំណងធានារ៉ាប់រងដែលត្រូវបានទទួលមុនហេតុការណ៍នោះ មានចំនួនតិចជាងបុព្វលាភធានារ៉ាប់រងសរុបដែលបានបង់ ក្រុមហ៊ុនធានារ៉ាប់រងនឹងប្រគល់ត្រឡប់នូវបុព្វលាភដែលអ្នកស្នើសុំបានបង់ដោយមិនមានការប្រាក់ ដកចេញនូវចំនួនសំណងដែលធ្លាប់បានទទួលទៅឲ្យអ្នកស្នើសុំធានារ៉ាប់រងវិញ ហើយកិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់។

ចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងរហូតដល់កាលបរិច្ឆេទផុតកំណត់នៃរយៈពេលធានារ៉ាប់រង ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ហើយចំនួនសំណងធានារ៉ាប់រងដែលបានទទួលមុនហេតុការណ៍នោះ គឺមានចំនួនច្រើនជាងឬស្មើនឹងផលបូកនៃបុព្វលាភដែលបានបង់រួច នោះក្រុមហ៊ុនធានារ៉ាប់រងនឹងមិនប្រគល់ត្រឡប់នូវបុព្វលាភដែលបានបង់រួចទៅឲ្យអ្នកស្នើសុំធានារ៉ាប់រងវិញទេ ហើយកិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់។

9. **ករណីមិនធានា**

នៅក្នុងកាលៈទេសៈណាក៏ដោយដូចមានរៀបរាប់ខាងក្រោម ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានទំនួលខុសត្រូវលើវិសាលភាពនៃការធានាក្នុងប្រការ ៨ នៃកិច្ចសន្យាធានារ៉ាប់រងនេះឡើយ បើមានករណីណាមួយដូចខាងក្រោម÷

១. អ្នកស្នើសុំធានារ៉ាប់រងបានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺ ឬធ្វើអត្តឃាតដោយចេតនា ដើម្បីទទួលបានសិទ្ធិលើកលែងចំពោះបុព្វលាភធានារ៉ាប់រងនៅក្រោមចំនុច (១) ប្រការ ៨ នៃកិច្ចសន្យាធានារ៉ាប់រង

២. អ្នកស្នើសុំធានារ៉ាប់រងដោយសារតែការវាយតប់គ្នា ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ការបើកបរក្នុងស្ថានភាពស្រវឹង ការបើកបរក្នុងស្ថានភាពគ្រោះថ្នាក់ ការបើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ ឬការបើកបរយានយន្តដោយគ្មានការចុះបញ្ជីត្រឹមត្រូវដែលបានកំណត់ដោយច្បាប់ បណ្តាលឲ្យទទួលមរណភាព

៣. អ្នកស្នើសុំធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការជ្រមុជទឹក ការលោតឆត្រយោង ការឡើងភ្នំ ការផ្សងព្រេង ការសម្តែងបច្ចេកទេសពិសេស ការប្រណាំងរថយន្ត ដែលបណ្តាលទទួលមរណភាព

៤. ការពិនិត្យមុន និងក្រោយមានផ្ទៃពោះ ការមានផ្ទៃពោះ (រួមមានកូនក្រៅស្បូន) ការរលូតកូន (រួមទាំងការរំលូតកូន) ការសម្រាលកូន (រួមទាំងការសម្រាលកូនដោយវះកាត់) ការពន្យារកំណើត ការវះកាត់មិនឲ្យមានកូន ការព្យាបាលឲ្យមានកូន និងជំងឺផ្សេងទៀត

ដែលវិវឌ្ឍន៍ចេញពីជំងឺខាងលើនេះរបស់អ្នកស្នើសុំធានារ៉ាប់រង ដែលបណ្តាលអោយកើតមានគ្រោះថ្នាក់ស្ថិតក្រោមវិសាលភាពនៃការធានាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ

៥. អ្នកស្នើសុំធានារ៉ាប់រងទទួលរងនូវឧប្បត្តិហេតុខាងវេជ្ជសាស្ត្រដោយសារការវះកាត់កែសម្ផស្ស ឬការវះកាត់ផ្សេងៗ ដែលបណ្តាលទទួលមរណភាព

៦. សង្គ្រាម ការប៉ះទង្គិចផ្នែកយោធា ការបះបោរឬការបះបោរប្រដាប់អាវុធ ព្រមទាំងការផ្ទុះនុយក្លេអ៊ែរ ការសាយភាយវិទ្យុសកម្មនុយក្លេអ៊ែរ ឬផលប៉ះពាល់ដោយនុយក្លេអ៊ែរ ដែលបណ្តាលឲ្យអ្នកស្នើសុំធានារ៉ាប់រងទទួលមរណភាព។

**10. អ្នកទទួលផល**

អ្នកត្រូវបានធានារ៉ាប់រង ដូចមានបញ្ជាក់នៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ គឺជាអ្នកទទួលផលពីកិច្ចសន្យាធានារ៉ាប់រង។

ប្រសិនបើអ្នកទទួលផលមិនមានសមត្ថភាពផ្នែកស៊ីវិល ឬត្រូវបានរឹតត្បិតសមត្ថភាពស៊ីវិល នោះអាណាព្យាបាលរបស់អ្នកទទួលផលនឹងត្រូវចាត់តាំងជាអ្នកតំណាងរបស់អ្នកទទួលផល។

**11. ការជូនដំណឹងអំពីព្រឹត្តិការណ៍ស្ថិតក្រោមវិសាលភាពនៃការធានា**

អ្នកស្នើសុំធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលត្រូវមានកាតព្វកិច្ចជូនដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រងឲ្យបានទាន់ពេលវេលា បន្ទាប់ពីបានដឹងអំពីព្រឹត្តិការណ៍ស្ថិតក្រោមវិសាលភាពនៃការធានា។

**12. ការទាមទារ និងការទូទាត់សំណង**

(1) អ្នកទាមទារសំណងធានារ៉ាប់រង ឬអ្នកទាមទារការលើកលែងបុព្វលាភធានារ៉ាប់រង ត្រូវផ្តល់ភស្តុតាង ព្រមទាំងឯកសារតម្រូវផ្សេងៗ ដូចមានចែងនៅក្នុងប្រការ ១៣ នៃ ខ និងលក្ខខណ្ឌធានារ៉ាប់រងក្នុងកិច្ចសន្យានេះ។ ប្រសិនបើភស្តុតាង និងឯកសារផ្សេងៗមិនទាន់ត្រូវបានផ្តល់ឲ្យទេ ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងភ្លាមទៅអ្នកទាមទារសំណងឲ្យផ្តល់ឯកសារ និងភស្តុតាងបន្ថែមទៀត។ អ្នកទាមទារសំណងត្រូវមានកាតព្វកិច្ចផ្តល់នូវភស្តុតាងពាក់ព័ន្ធ និងឯកសារដែលបានបញ្ជាក់ផ្សេងៗខាងលើឲ្យបានឆាប់រហ័ស។

(2) នៅពេលទទួលសំណុំបែបបទស្នើសុំទាមទារសំណង និងភស្តុតាង ក៏ដូចជាឯកសារដូចដែលបានបញ្ជាក់នៅខាងលើនេះ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្ទៀងផ្ទាត់ក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ ឬ ២០ ថ្ងៃនៃថ្ងៃធ្វើការសម្រាប់ករណីស្មុគស្មាញ។

បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់រួច ប្រសិនបើត្រូវបានបញ្ជាក់ថាត្រូវធ្វើការទូទាត់សង នោះក្រុមហ៊ុនធានារ៉ាប់រងនឹងទូទាត់សំណងក្នុងរយៈពេល ២ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានព្រមព្រៀងគ្នាជាមួយអ្នកទាមទារសំណងលើការទូទាត់សំណងនេះ។ បន្ទាប់ពីពិនិត្យផ្ទៀងផ្ទាត់រួចហើយ ប្រសិនបើត្រូវបានបញ្ជាក់ថាមិនត្រូវធ្វើការទូទាត់សងទេនោះ ក្រុមហ៊ុនធានារ៉ាប់រងនឹងចេញលិខិតជូនដំណឹងមួយស្តីពីការបដិសេធក្នុងការទូទាត់សំណងធានារ៉ាប់រងទៅអ្នកដាក់ពាក្យទាមទារសំណងក្នុងរយៈពេល ២ថ្ងៃនៃថ្ងៃធ្វើការ ដោយមានការពន្យល់បញ្ជាក់អំពីមូលហេតុពីការបដិសេធនោះផងដែរ។

(3) រយៈពេលមានប្រសិទ្ធភាព សម្រាប់អ្នកទទួលផលស្នើសុំការលើកលែងបង់បុព្វលាភធានារ៉ាប់រងសេសសល់ដែលត្រូវបង់ គឺមានរយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃដែលអ្នកទទួលផលបានដឹង ឬគួរដឹងអំពីគ្រោះថ្នាក់ស្ថិតក្រោមការធានារ៉ាប់រង ប៉ុន្តែសម្រាប់ការទាមទារអត្ថប្រយោជន៍សម្រាប់ការអប់រំមានរយៈពេល៥ឆ្នាំ ។

**13. ភស្តុតាង និងឯកសារតម្រូវសម្រាប់ការទាមទារសំណងធានារ៉ាប់រង**

(1) កិច្ចសន្យាធានារ៉ាប់រង ឬភស្តុតាងផ្សេងទៀតដែលបង្ហាញថាកិច្ចសន្យាធានារ៉ាប់រងនៅមានអនុភាព

(2) ឯកសារបញ្ជាក់ពីអត្តសញ្ញាណស្របច្បាប់ដែលមានសុពលភាពរបស់អ្នកទទួលផល

(3) ភស្តុតាង និងឯកសារដែលបង្ហាញពីអង្គហេតុ លក្ខណៈដើម និងមូលហេតុនៃគ្រោះថ្នាក់ដែលមាន ហើយដែលនឹងត្រូវផ្តល់ជូនក្រុមហ៊ុនធានារ៉ាប់រងដោយអ្នកស្នើសុំធានារ៉ាប់រង

(4) ប្រសិនបើមានអ្នកតំណាងម្នាក់ត្រូវបានតែងតាំងដើម្បីទាមទារសំណង ត្រូវផ្តល់នូវលិខិតប្រគល់សិទ្ធិតំណាង និងឯកសារអត្តសញ្ញាណរបស់អ្នកតំណាង

(5) ភស្តុតាង និងឯកសារដូចខាងក្រោមនឹងត្រូវផ្តល់ ប្រសិនបើការទាមទារត្រូវបានធ្វើឡើងសម្រាប់ការស្នើសុំលើកលែងបង់បុព្វលាភធានារ៉ាប់រងសេសសល់ដែលត្រូវបង់÷

1) លិខិតដែលមានប្រសិទ្ធភាពស្របច្បាប់ដើម្បីបញ្ជាក់ថាអ្នកស្នើសុំធានារ៉ាប់រងបានស្លាប់បាត់បង់ជីវិតដោយចៃដន្យ

2) ការប្រកាសអំពីមរណភាពដែលមានប្រសិទ្ធិភាពស្របច្បាប់ ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងត្រូវបានប្រកាសថាស្លាប់បាត់បង់ជីវិត ដោយសារតែការបាត់ខ្លួនដោយចៃដន្យ

3) លិខិតបញ្ជាក់អំពីការលុបចោលការចុះបញ្ជីគ្រួសាររបស់អ្នកដែលបានដាក់ពាក្យស្នើសុំធានារ៉ាប់រង។

**14. ការបាត់ខ្លួន**

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងបាត់ខ្លួននៅពេលគ្រោះថ្នាក់ជាយថាហេតុ និងត្រូវបានប្រកាសថាស្លាប់ដោយតុលាការ ក្រុមហ៊ុនធានារ៉ាប់រងត្រូវលើកលែងចំពោះការបង់បុព្វលាភជាបន្តបន្ទាប់ដោយអនុលោមតាមចំណុច ១ ប្រការ ៨ នៃកិច្ចសន្យាធានារ៉ាប់រង ប៉ុន្តែពេលវេលានៃការស្លាប់របស់អ្នកស្នើសុំធានារ៉ាប់រង ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការប្រកាសពីការស្លាប់ដោយតុលាការ។

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងរកឃើញវិញ ឬត្រូវបានបញ្ជាក់ថាមានជីវិតនៅឡើយបន្ទាប់ពីការប្រកាសមរណភាព សេចក្តីសម្រេចរបស់ក្រុមហ៊ុនធានារ៉ាប់រងចំពោះការលើកលែងលើប្រាក់សំណងនឹងត្រូវអស់សុពលភាព អ្នកស្នើសុំធានារ៉ាប់រងត្រូវទូទាត់សងតាមកាលវិភាគ និងបង់បន្ថែមនូវបុព្វលាភដែលបានលើកលែង ទើបអាចរក្សាសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រង។

**15. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រងដោយអ្នកស្នើសុំធានារ៉ាប់រង**

លើកលែងតែមានការចែងផ្សេងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង បន្ទាប់ពីកិច្ចសន្យាធានារ៉ាប់រងត្រូវបានបង្កើត អ្នកស្នើសុំធានារ៉ាប់រងអាចស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងបាន។

សម្រាប់កិច្ចសន្យាធានារ៉ាប់រង ដែលបានទទួលសិទ្ធិលើកលែងនូវបុព្វលាភធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងមិនអាចទទួលយកសំណើរសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងឡើយ។

កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងទទួលបានសំណើបញ្ចប់កិច្ចសន្យាធានារ៉ាប់រង។ ក្រុមហ៊ុនធានារ៉ាប់រងនឹងត្រូវទូទាត់តម្លៃសាច់ប្រាក់របស់កិច្ចសន្យានៅពេលនោះជូនអ្នកស្នើសុំធានារ៉ាប់រងក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលសំណើបញ្ចប់កិច្ចសន្យាធានារ៉ាប់រងរបស់អ្នកស្នើសុំធានារ៉ាប់រង។

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ក្នុងអំឡុងពេលធ្វើការសម្រេចចិត្ត អ្នកស្នើសុំធានារ៉ាប់រងត្រូវទទួលខុសត្រូវចំពោះការបាត់បង់ផ្នែកសេដ្ឋកិច្ចដែលកើតឡើងពីការបញ្ចប់កិច្ចសន្យានោះ។

**16. តម្លៃសាច់ប្រាក់**

តម្លៃសាច់ប្រាក់សំដៅទៅលើការបញ្ចប់កិច្ចសន្យានៅក្នុងអំឡុងពេលធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្អែកតាមបទបញ្ញាតិនៃកិច្ចសន្យាធានារ៉ាប់រងផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រងមួយចំនួនទៅឱ្យអ្នកស្នើសុំធានារ៉ាប់រងវិញ។ តម្លៃសាច់ប្រាក់នៅចុងឆ្នាំនៃកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវបញ្ជាក់ច្បាស់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ សូមមើលតារាងឧបសម្ព័ន្ធ២÷ (តារាងតម្លៃសាច់ប្រាក់នៅចុងឆ្នាំនីមួយៗនៃបណ្ណសន្យារ៉ាប់រងក្នុងមួយច្បាប់)។ តម្លៃសាច់ប្រាក់ក្នុង ខ និងលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងត្រូវគណនាដោយយោងតាមតារាងនេះ។ នៅពេលបញ្ចប់កិច្ចសន្យានៅក្នុងអំឡុងពេលធានារ៉ាប់រង ក្រុមហ៊ុននឹងគណនាផ្អែកតាមតារាងឧបសម្ព័ន្ធ២ ព្រមទាំងផ្អែកតាមចំនួនឆ្នាំនិងថ្ងៃដែលបានឆ្លងកាត់របស់បណ្ណសន្យារ៉ាប់រង។

**17. បណ្ណសន្យាឥណទាន**

(1) ក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងមានអនុភាព អ្នកស្នើសុំធានារ៉ាប់រងអាចស្នើសុំប្រាក់កម្ចីដោយប្រើប្រាស់កិច្ចសន្យាធានារ៉ាប់រងជាទ្រព្យដាក់ធានាបាន បន្ទាប់ពីទទួលបានការយល់ព្រមពីក្រុមហ៊ុនធានារ៉ាប់រង។ ចំនួនប្រាក់កម្ចីមិនត្រូវលើសពី ៧០% នៃសមតុល្យតម្លៃសាច់ប្រាក់នៅពេលនោះ បន្ទាប់ពីដកយកនូវចំនួនប្រាក់ដែលមិនបានបង់។ រយៈពេលអតិបរមានៃកម្ចីនីមួយៗមិនត្រូវមានរយៈពេលលើសពី ១២ខែ និងអត្រាការប្រាក់គឺ ៦% ក្នុងមួយឆ្នាំ។ ប្រសិនបើប្រាក់ដើម និងការប្រាក់នៃប្រាក់កម្ចីមិនត្រូវបានសង ឬសងមិនគ្រប់ចំនួននៅពេលដែលកាលកំណត់ត្រូវសងមកដល់ ប្រាក់ដើម និងការប្រាក់នឹងក្លាយទៅជាមូលដ្ឋានសម្រាប់គណនាប្រាក់ចំណាយសម្រាប់អាណត្តិថ្មី។

(2) កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវផ្អាក ហើយក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានកាតព្វកិច្ចត្រូវសងសំណង គិតចាប់ពីថ្ងៃបន្ទាប់នៃកាលបរិច្ឆេទដែលប្រាក់ដើម ការប្រាក់ និងចំនួនប្រាក់ដែលនៅសល់នៃប្រាក់កម្ចីមានចំនួនស្មើនឹងចំនួនទឹកប្រាក់ដែលនៅសល់នៃតម្លៃសាច់ប្រាក់សុទ្ធ ។

**18. ការផ្អាក និងការបន្តកិច្ចសន្យាធានារ៉ាប់រង**

កិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវផ្អាក ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងខកខានមិនបានបង់បុព្វលាភធានារ៉ាប់រងឲ្យបានទាន់ពេលវេលា យោងតាមបទប្បញ្ញត្តិនៃកិច្ចសន្យាធានារ៉ាប់រងនេះ ឬកើតមានព្រឹត្តិការណ៍ដូចមានចែងក្នុងប្រការ ១៧ កថាខណ្ឌទី២នៃ ខ និងលក្ខខណ្ឌក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ។

ក្នុងរយៈពេលពីរឆ្នាំបន្ទាប់ពីការផ្អាកកិច្ចសន្យាធានារ៉ាប់រង អ្នកស្នើសុំធានារ៉ាប់រងអាចស្នើសុំបន្តកិច្ចសន្យាធានារ៉ាប់រងឡើងវិញ ហើយកិច្ចសន្យាធានារ៉ាប់រងនឹងបន្តឡើងវិញចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃដែលអ្នកស្នើសុំធានារ៉ាប់រងបំពេញបែបបទដើម្បីបន្តកិច្ចសន្យាធានារ៉ាប់រង និងបង់បុព្វលាភរួមជាមួយនឹងការប្រាក់ ព្រមទាំងបង់ ប្រាក់ដែលនៅសល់ផ្សេងទៀតរួមជាមួយការប្រាក់គ្រប់ចំនួន។ ការប្រាក់ត្រូវបានគណនាយោងតាមអត្រាការប្រាក់៦%ក្នុងមួយឆ្នាំ។

គិតចាប់ពីថ្ងៃផ្អាកកិច្ចសន្យាធានារ៉ាប់រងរហូតដល់គ្រប់រយៈពេលពីរឆ្នាំ កិច្ចសន្យាធានារ៉ាប់រងនឹងអស់សុពលភាពជាអចិន្ត្រៃយ៍។ ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនទទួលយកសំណើសុំបន្តកិច្ចសន្យាធានារ៉ាប់រងឡើយ។ នៅពេលដែលអ្នកស្នើសុំបំពេញបែបបទនៃការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់ត្រឡប់នូវតម្លៃសាច់ប្រាក់របស់កិច្ចសន្យានៅពេលដែលផ្អាកកិច្ចសន្យាធានារ៉ាប់រងទៅឲ្យអ្នកស្នើសុំធានារ៉ាប់រង។

**19. ការពន្យល់ឲ្យបានច្បាស់ និងការផ្តល់ពត៌មានពិត**

នៅពេលអនុវត្តកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងត្រូវពន្យល់អ្នកស្នើសុំធានារ៉ាប់រងឲ្យបានច្បាស់អំពីខ្លឹមសារនៃកិច្ចសន្យាធានារ៉ាប់រង។

ចំពោះករណីមិនធានាដូចមានចែងក្នុង ខ និងលក្ខខណ្ឌផ្សេងៗនៃការធានារ៉ាប់រង និងលក្ខខណ្ឌចាំបាច់ផ្សេងទៀត ដូចជាការទទួលខុសត្រូវចំពោះការបាត់បង់ផ្នែកសេដ្ឋកិច្ចដោយសារតែការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ដោយអ្នកស្នើសុំធានារ៉ាប់រងក្នុងអំឡុងពេលធ្វើការសម្រេចចិត្ត ក្រុមហ៊ុនធានារ៉ាប់រងត្រូវបង្ហាញអ្នកស្នើសុំធានារ៉ាប់រងនូវ សៀវភៅផែនការធានារ៉ាប់រង ពាក្យស្នើសុំធានារ៉ាប់រង កិច្ចស្យាធានារ៉ាប់រង ឬឯកសារធានារ៉ាប់រងផ្សេងៗទៀត នៅពេលអនុវត្តកិច្ចសន្យាធានារ៉ាប់រង។

ក្រុមហ៊ុនធានារ៉ាប់រង អាចសាកសួរអ្នកស្នើសុំធានារ៉ាប់រងអំពីពត៌មានផ្ទាល់ខ្លួន ស្ថានភាពសុខភាព ប្រវត្តិជំងឺពីមុនប្រវត្តិជំងឺក្នុងគ្រួសាររបស់អ្នកស្នើសុំធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង និងបញ្ហាផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តកិច្ចសន្យាធានារ៉ាប់រង។ អ្នកស្នើសុំធានារ៉ាប់រងត្រូវអនុវត្តកាតព្វកិច្ចផ្តល់ពត៌មានពិតដោយសុចរិតត្រឹមត្រូវ។

ប្រសិនបើអ្នកស្នើសុំមានចេតនាមិនអនុវត្តកាតព្វកិច្ចផ្តល់ពត៌មានពិត ឬផ្តល់ពត៌មានក្លែងក្លាយ ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានទំនួលខុសចំពោះព្រឹត្តិការណ៍ស្ថិតក្រោមវិសាលភាពនៃការធានាដែលកើតឡើងមុនពេលបញ្ចប់កិច្ចសន្យាធានារ៉ាប់រងឡើយ។ ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងមិនត្រូវប្រគល់បុព្វលាភដែលបានបង់រួចនោះទេ។

**20. ការកែប្រែខ្លឹមសារនៃកិច្ចសន្យាធានារ៉ាប់រង**

អ្នកស្នើសុំធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងអាចចរចារដើម្បីធ្វើការកែប្រែលើខ្លឹមសារនៃកិច្ចសន្យាធានារ៉ាប់រងបាន។ រាល់ខ្លឹមសារដែលកែប្រែ នឹងមានការយល់ព្រមនៅលើកិច្ចសន្យាធានារ៉ាប់រង ឬឯកសារធានារ៉ាប់រងផ្សេងទៀត ឬបន្ថែមនូវកិច្ចសន្យាបន្ថែម ឬតម្រូវឲ្យអ្នកស្នើសុំធានារ៉ាប់រងចុះកិច្ចសន្យាអំពីការកែប្រែនោះជាលាយលក្ខណ៍អក្សរជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រង។

ក្នុងករណីដែលអ្នកស្នើសុំធានារ៉ាប់រងប្តូរអាសយដ្ឋានទំនាក់ទំនង និងពត៌មានទំនាក់ទំនងរបស់គាត់ អ្នកស្នើសុំធានារ៉ាប់រងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមមកក្រុមហ៊ុនធានារ៉ាប់រង។ ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងខកខានក្នុងការអនុវត្តន៍កាតព្វកិច្ចនេះ ក្រុមហ៊ុនធានារ៉ាប់រងនឹងជូនដំណឹងផ្សេងៗតាមរយៈអាសយដ្ឋានទំនាក់ទំនង និងពត៌មានទំនាក់ទំនងចុងក្រោយដែលក្រុមហ៊ុនបានស្គាល់ទៅអ្នកស្នើសុំធានារ៉ាប់រង។

អ្នកស្នើសុំធានារ៉ាប់រងត្រូវតែបំពេញអាយុពិតប្រាកដរបស់អ្នកស្នើសុំនិងអ្នកត្រូវបានធានារ៉ាប់រងលើពាក្យស្នើសុំធានារ៉ាប់រង។ ក្នុងករណីមានកំហុសឆ្គងណាមួយបានកើងឡើង អ្នកស្នើសុំធានារ៉ាប់រង ត្រូវចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរដើម្បីកែប្រែពត៌មានអំពីអាយុជាមួយក្រុមហ៊ុនធានារ៉ាប់រង ហើយបុព្វលាភធានារ៉ាប់រងត្រូវគណនាឡើងវិញ ដោយផ្អែកលើអាយុពិតប្រាកដ។ បុព្វលាភធានារ៉ាប់រងត្រូវប្រគល់ជូនវិញ ប្រសិនបើបានទូទាត់លើស ហើយត្រូវបន្ថែមមកវិញប្រសិនបើទូទាត់ខ្វះ។

ក្នុងករណីដែលអ្នកស្នើសុំធានារ៉ាប់រងផ្តល់ពត៌មានមិនពិតអំពីអាយុរបស់អ្នកស្នើសុំ ឬអ្នកត្រូវបានធានារ៉ាប់រង ហើយអាយុពិតប្រាកដរបស់អ្នកស្នើសុំ ឬអ្នកត្រូវបានធានារ៉ាប់រង គឺមិនសមស្របទៅនឹងការកំណត់អាយុក្រោមបទបញ្ញត្តិនៃកិច្ចសន្យា

ធានារ៉ាប់រង ក្រុមហ៊ុនមានសិទ្ធិដឹងអំពីមូលហេតុនៃការបញ្ចប់កិច្ចសន្យាក្នុងរយៈពេល៣០ថ្ងៃ ហើយក្រោយពីបានដឹងអំពីមូលហេតុនោះក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិដូចតទៅ÷

(1) សម្រាប់ប្រាក់សំណងដែលបានទូទាត់រួច ក្រុមហ៊ុននឹងប្រគល់ជូនវិញតែតម្លៃសាច់ប្រាក់នៃកិច្ចសន្យាធានារ៉ាប់រងទៅឱ្យអ្នកស្នើសុំធានារ៉ាប់រង។

(2) សម្រាប់ប្រាក់សំណងមិនទាន់ត្រូវបានទូទាត់ ក្រុមហ៊ុននឹងប្រគល់ជូនវិញនូវប្រាក់បុព្វលាភដែលបានបង់ដោយគ្មានការប្រាក់ទៅឱ្យអ្នកស្នើសុំធានារ៉ាប់រង ហើយត្រូវបង់ចំនួន ១០ដុល្លារសហរដ្ឋអាមេរិកសម្រាប់ថ្លៃសេវាកម្ម។

**21. ការដោះស្រាយវិវាទ**

ចំពោះគ្រប់វិវាទដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុន នឹងប្ដឹងទៅវេទិកាមជ្ឈត្តកម្មឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្ដល់ជូនអ្នកស្នើសុំធានារ៉ាប់រងនូវ ខ និងលក្ខខណ្ឌជាភាសាខ្មែរ។ ចំពោះភាសាអង់គ្លេស និងភាសាចិននឹងត្រូវបានផ្ដល់ជូនយោងតាមសំណូមពររបស់អ្នកស្នើសុំធានារ៉ាប់រង ប៉ុន្តែក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយកភាសាខ្មែរជាគោល។

**22. និយមន័យ**

<u>ក្រុមហ៊ុនធានារ៉ាប់រង</u>÷ សំដៅលើក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្គ្រេន ឆាយណា ឡាយហ្វ៍ អ៊ិនសួរេន ភីអិលស៊ី។

<u>អាយុ</u>÷ សំដៅដល់អាយុដែលត្រូវបានគណនាដោយផ្អែកលើថ្ងៃខែឆ្នាំកំណើតដែលបានបញ្ជាក់នៅលើអត្តសញ្ញាណបណ្ណដែលត្រូវនឹងអាយុសូន្យ គិតចាប់ពីថ្ងៃខែឆ្នាំកំណើត និងកើនឡើង ១ឆ្នាំនៅពេលដែលមួយឆ្នាំបានកន្លងផុតទៅ ហើយនឹងមិនត្រូវបានរាប់ជាមួយឆ្នាំទេ ប្រសិនបើមួយឆ្នាំមិនទាន់កន្លងផុត។

<u>ឯកសារបញ្ជាក់ពីអត្តសញ្ញាណស្របច្បាប់</u>÷សំដៅទៅលើលិខិតបញ្ជាក់ឬឯកសារដូចជាអត្តសញ្ញាណបណ្ណ លិខិតឆ្លងដែនជាដើម ដែលចេញដោយរដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណ។

<u>គ្រោះថ្នាក់ជាយថាហេតុ</u>÷ សំដៅទៅលើគ្រោះថ្នាក់ ដែលជាគ្រោះថ្នាក់ខាងក្រៅ មិនអាចរំពឹងទុកបាន មិនមានឆន្ទះគ្មានជំងឺ និងបង្កឱ្យមានរបួសដោយផ្ទាល់។ គ្រោះថ្នាក់ រួមមានការផ្ទុះ ការដួលរលំ ការរលាក ការប៉ះទង្គិចគ្នា ផ្លេកបន្ទោរ ការឆក់ចរន្តអគ្គិសនី គ្រេចថ្លោះ ការកក ខ្យល់ករ ការលង់ទឹក ការថប់ដង្ហើម ការដួល ការពុល សត្វខាំ ការប៉ះទង្គិចយានយន្ត ទូក ឬយន្តហោះ គ្រោះថ្នាក់ការងារដែលបណ្ដាលមកពីការធ្វើការងារលើសម៉ោង។ ការស្លាប់ភ្លាមៗមិនត្រូវបានចាត់ទុកថាជាការស្លាប់ដោយចៃដន្យ(ការស្លាប់ភ្លាមៗ សំដៅទៅលើមរណភាពភ្លាមៗ ដោយគ្មានអំពើហឹង្សាលើអ្នកស្លាប់ ដែលមើលទៅមានសុខភាពល្អក្នុងរយៈពេល ២៤ម៉ោងបន្ទាប់ពីមានរោគសញ្ញាកើតឡើងតាមរយៈជំងឺដែលបានកំណត់ ដំណើរការខុសប្រក្រតី ឬមូលហេតុផ្សេងទៀត។ ការស្លាប់ភ្លាមៗនឹងត្រូវកំណត់ដោយអ្នកធ្វើរោគវិនិច្ឆ័យនៅមន្ទីរពេទ្យ និងផ្ដល់យថាភូតដោយមន្ត្រីប៉ូលីស។

<u>ឆ្នាំនៃបណ្ណសន្យារ៉ាប់រង</u>÷ ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចសន្យាធានារ៉ាប់រង (ឬខួបប្រចាំឆ្នាំនៃថ្ងៃចូលជាធរមាន) ដល់ថ្ងៃខែឆ្នាំដែលមានប្រសិទ្ធភាពក្នុងឆ្នាំបន្ទាប់។

<u>គម្រប់ខួបប្រសិទ្ធិភាព</u>÷ ការគម្រប់ខួបប្រចាំឆ្នាំ (ឆមាស ត្រីមាស ឬប្រចាំខែ) នៃកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃកិច្ចសន្យាធានារ៉ាប់រងសម្រាប់ឆ្នាំនីមួយៗ(ឆមាស ត្រីមាស ឬខែ) ។

<u>គ្រឿងញៀន</u>÷ សំដៅលើថ្នាំអាភៀន ហេរ៉ូអ៊ីន មេតំហ្វេតាមីន ថ្នាំម៉ុនហ្វីន ថ្នាំញៀនកូកាអ៊ីនគីទីន (K powder) ដែលកំណត់ដោយអង្គការសហប្រជាជាតិ និងគ្រឿងញៀន និងគ្រឿងញៀនផ្សេងទៀតដែលត្រូវបានហាមឃាត់ លើកលែងតែថ្នាំពេទ្យដែលមានសមាសធាតុគ្រឿងញៀន ប៉ុន្តែត្រូវបានចេញវេជ្ជបញ្ជាដោយវេជ្ជបណ្ឌិត និងត្រូវបានប្រើប្រាស់តាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិតសម្រាប់ការព្យាបាលជំងឺ។

<u>ការបើកបរក្នុងស្ថានភាពស្រវឹង</u>÷ សំដៅទៅលើព្រឹត្តិការណ៍ដែលអ្នកបើកបរត្រូវបានធ្វើតេស្ត ឬផ្ទៀងផ្ទាត់កម្រិតជាតិអាល់កុល ដែលអាចផ្ទុកបរិមាណចំនួនមួយរយមីលីលីត្រ ដែលមាននៅក្នុងឈាមរបស់បុគ្គលនោះ ដែលកម្រិតជាតិអាល់កុលនោះអាចឈានដល់ ឬលើសពីកម្រិតដែលកំណត់ដោយច្បាប់ ឬរដ្ឋាភិបាល។

<u>ការបើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ</u> ÷ សំដៅទៅលើស្ថានភាពណាមួយដូចខាងក្រោម÷

(1) មិនទទួលបានសិទ្ធិបើកបរ

(2) បើកបររថយន្តដែលមិនត្រូវគ្នានឹងបណ្ណបើកបរ

(3) មានអាជ្ញាបណ្ណបើកបរមិនមានសុពលភាព

(4) មានអាជ្ញាបណ្ណរៀនសូត្រ និងរៀនបើកឡានដោយគ្មានការណែនាំពីអ្នកបង្រៀនបើកបរ ឬមិនអនុវត្តតាមពេលកំណត់ និងរៀនតាមផ្លូវបើកបរ។

<u>ការបើកបរយានយន្តដោយគ្មានការចុះបញ្ជីត្រឹមត្រូវ</u>÷ សំដៅទៅលើស្ថានភាពណាមួយខាងក្រោម÷

(1) យានយន្តដែលត្រូវបានលុបចោលស្របតាមច្បាប់

(2) មិនទាន់ទទួលបាន ឬឆ្លងកាត់ការត្រួតពិនិត្យបច្ចេកទេសសុវត្ថិភាពលើយានយន្តជាទៀងទាត់។

<u>យានយន្ត</u>÷ សំដៅដល់យានដែលធ្វើចរាចរណ៍ដោយម៉ាស៊ីនលើផ្លូវគោក និងផ្លូវទឹក។

<u>ជំងឺតំណពូជ</u>÷ គឺជាជំងឺដែលបណ្តាលមកពីការខ្វះចន្លោះ ការផ្លាស់ប្តូរ ឬការខូចទ្រង់ទ្រាយនៃហ្សែន (ក្រូម៉ូសូម និងហ្សែន) នៃកោសិកាបន្តពូជ ឬស៊ុតបង្កកំណើត ដែលជាទូទៅត្រូវបានសម្គាល់ដោយការបញ្ជូនពីឪពុកម្តាយទៅកូន។

<u>ភាពមិនប្រក្រតីពីកំណើត ភាពខុសប្រក្រតី ឬភាពមិនប្រក្រតីនៃក្រូម៉ូសូម</u>÷ សំដៅលើភាពមិនប្រក្រតីពីកំណើត ឬភាពមិនប្រក្រតីនៃក្រូម៉ូសូមដែលមានចំពោះអ្នកត្រូវបានធានារ៉ាប់រងតាំងពីកំណើត។ ភាពមិនប្រក្រតីពីកំណើត ភាពខុសគ្នា និងភាពមិនប្រក្រតីនៃក្រូម៉ូសូម ត្រូវបានកំណត់ដោយយោងតាម "ចំណាត់ថ្នាក់ស្ថិតិអន្តរជាតិនៃជំងឺ និងបញ្ហាសុខភាពដែលពាក់ព័ន្ធ (ICD-10)" របស់អង្គការសុខភាពពិភពលោក។

<u>ការមុជទឹក</u>÷ សំដៅលើសកម្មភាពក្រោមទឹកនៅក្នុងទន្លេ បឹង សមុទ្រ អាងស្តុកទឹក ប្រឡាយ និងតំបន់ទឹកផ្សេងៗទៀតដោយប្រើឧបករណ៍ជំនួយដកដង្ហើម។

<u>ការឡើងភ្នំ</u>÷ សំដៅលើសកម្មភាពនៃការឡើងភ្នំថ្មចំាងថ្ម ការសាងសង់ភ្នំ ច្រាំងថ្មចោទដែលមនុស្សបង្កើត ជ្រោះទឹកកក និងភ្នំទឹកកក។

<u>ដំណើរផ្សងព្រេង</u>÷ សំដៅទៅលើការដាក់ខ្លួនដោយចេតនាទៅក្នុងកាលៈទេសៈណាមួយដោយដឹងថាវាអាចបង្កឱ្យមានហានិភ័យដល់បាត់បង់ជីវិត ឬរងរបួសនៅក្រោមលក្ខខណ្ឌធម្មជាតិជាក់លាក់។ ឧទាហរណ៍÷ ការបណ្តែតខ្លួនតាមដងទន្លេ ភ្នំ ដើរតាមវាលខ្សាច់ ឬព្រៃស្រោងដែលមិនអាចចូលទៅដល់បាន។

<u>ការសម្តែងជំនាញពិសេស</u>÷ សំដៅទៅលើការសម្តែងនៃការជិះសេះ ការលេងសៀក ការបង្វឹកសត្វ និងសកម្មភាពផ្សេងៗទៀត។

<u>ជំងឺសតិអារម្មណ៍ និងអាកប្បកិរិយាមិនប្រក្រតី</u>÷ ផ្អែកលើ "ចំណាត់ថ្នាក់ស្ថិតិអន្តរជាតិនៃជំងឺ និងបញ្ហាសុខភាពដែលពាក់ព័ន្ធ (ICD-10) " ចេញដោយអង្គការសុខភាពពិភពលោក។

<u>សង្គ្រាម</u>÷ សំដៅទៅលើការតស៊ូប្រដាប់អាវុធរវាងរដ្ឋ និងរដ្ឋ ប្រជាពលរដ្ឋ និងប្រជាពលរដ្ឋឬក្រុមនយោបាយ និងក្រុមនយោបាយ សម្រាប់គោលបំណងនយោបាយ និងសេដ្ឋកិច្ច ដោយផ្អែកលើសេចក្តីប្រកាសរបស់រដ្ឋាភិបាល។

<u>ការប៉ះទង្គិចផ្នែកយោធា</u>÷ សំដៅលើការប្រឈមមុខប្រដាប់អាវុធដាក់គ្នារវាងរដ្ឋ និងប្រជាពលរដ្ឋដែលស្ថិតនៅក្នុងវិសាលភាពជាក់លាក់ និងដោយផ្អែកលើសេចក្តីប្រកាសរបស់រដ្ឋាភិបាល។

<u>ការបះបោរឬការបះបោរប្រដាប់អាវុធ</u>÷ សំដៅលើការរំខានប្រដាប់អាវុធ ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមដោយផ្អែកលើសេចក្តីប្រកាសរបស់រដ្ឋាភិបាល។

<u>អ្នកស្នើសុំធានារ៉ាប់រង</u>÷ សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលអាចនឹងក្លាយជាអ្នកត្រូវបានធានារ៉ាប់រងនាពេលអនាគតដែលបំពេញនិងចុះហត្ថលេខាលើទម្រង់បែបបទជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុនធានារ៉ាប់រងអំពីស្ថានភាពផ្ទាល់របស់បុគ្គលនោះ។

<u>អ្នកត្រូវបានធានារ៉ាប់រង</u>÷ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទិញបណ្ណសន្យារ៉ាប់រង ក្នុងករណីមួយចំនួនអាចជាម្ចាស់បណ្ណសន្យារ៉ាប់រងផង និងអាចជាអ្នកត្រូវបានធានារ៉ាប់រងផង។

<u>អ្នកទទួលផល</u>÷ សំដៅដល់តតិយជននៃកិច្ចសន្យា ដែលត្រូវបានកំណត់ថាមានសិទ្ធិស្របច្បាប់ក្នុងការទទួលផលប្រយោជន៍ពីកិច្ចសន្យាទាំងឡាយណាដែលទាក់ទងនឹងការធានារ៉ាប់រងលើជីវិតតែប៉ុណ្ណោះ។

**23. តារាងឧបសម្ព័ន្ធ ១ និង ២**

**តារាងឧបសម្ព័ន្ធ ១៖ “តារាងអត្រាបុព្វលាភសម្រាប់គម្រោងអនាគតភ្លឺស្វាងមរុគ្គធីតាក្នុងមួយច្បាប់”**

រូបិយបណ្ណ៖ ដុល្លារសហរដ្ឋអាមេរិក

| តារាងអត្រាបុព្វលាភ | | | | | | |
|---|---|---|---|---|---|---|
| រយៈពេលបង់បុព្វលាភ / អាយុរបស់អ្នកត្រូវបានធានា នៅពេលដាក់ពាក្យស្នើសុំ | វិធីសាស្ត្រ A | | វិធីសាស្ត្រ B | | វិធីសាស្ត្រ C | |
| | 3ឆ្នាំ | 6ឆ្នាំ | 3ឆ្នាំ | 6ឆ្នាំ | 3ឆ្នាំ | 6ឆ្នាំ |
| 0 | 1,534.66 | 804.71 | 1,323.83 | 694.16 | 1,011.44 | 530.38 |
| 1 | 1,580.73 | 828.85 | 1,363.58 | 714.99 | 1,041.83 | 546.29 |
| 2 | 1,628.28 | 801.28 | 1,404.60 | 736.48 | 1,073.19 | 562.72 |
| 3 | 1,677.29 | 772.91 | 1,446.88 | 758.64 | 1,105.51 | 579.66 |
| 4 | 1,727.81 | 743.71 | 1,490.47 | 781.49 | 1,138.82 | 597.11 |
| 5 | 1,670.47 | 713.65 | 1,535.39 | 805.03 | 1,173.15 | 615.11 |
| 6 | 1,611.42 | 682.68 | 1,581.68 | 829.29 | 1,208.52 | 633.66 |
| 7 | 1,550.59 | 650.78 | 1,629.36 | 854.28 | 1,244.97 | 652.76 |
| 8 | 1,487.93 | 600.44 | 1,678.47 | 792.58 | 1,282.52 | 672.43 |
| 9 | 1,423.38 | 548.58 | 1,729.06 | 729.02 | 1,321.19 | 692.70 |
| 10 | 1,356.88 | 495.15 | 1,781.17 | 663.53 | 1,361.00 | 713.56 |
| 11 | 1,251.90 | 440.10 | 1,652.51 | 596.07 | 1,402.01 | 735.04 |
| 12 | 1,143.75 | 383.39 | 1,519.95 | 526.56 | 1,444.23 | 757.16 |
| 13 | 1,032.33 | 324.97 | 1,383.40 | 454.96 | 1,487.70 | 779.94 |
| 14 | 917.55 | 247.31 | 1,242.72 | 346.23 | 1,532.47 | 593.53 |

បញ្ជាក់: ការបង់បុព្វលាភប្រចាំឆមាស = យោងតាមការបង់បុព្វលាភប្រចាំឆ្នាំ x 0.52
ការបង់បុព្វលាភប្រចាំត្រីមាស= យោងតាមការបង់បុព្វលាភប្រចាំឆ្នាំ x 0.27
ការបង់បុព្វលាភប្រចាំខែ = យោងតាមការបង់បុព្វលាភប្រចាំឆ្នាំ x 0.09

**តារាងឧបសម្ព័ន្ធ ២៖ “តារាងតម្លៃសាច់ប្រាក់នៅចុងឆ្នាំនីមួយៗនៃបណ្ណសន្យារ៉ាប់រងក្នុងមួយច្បាប់”**
**(រួមបញ្ចូលអត្ថប្រយោជន៍សម្រាប់ការអប់រំ)**

រូបិយបណ្ណ៖ ដុល្លារសហរដ្ឋអាមេរិក

| តម្លៃសាច់ប្រាក់សម្រាប់វិធីសាស្ត្រ B (ការបង់បុព្វលាភរយៈពេល៦ឆ្នាំ) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ខួបនៃបណ្ណសន្យារ៉ាប់រង/អាយុ | 0 | 1 | 2 | 3 | 4 | 5 | 6 | 7 | 10 | 14 |
| 1 | 387.02 | 398.87 | 411.01 | 423.49 | 436.31 | 449.51 | 463.09 | 477.07 | 370.54 | 193.35 |
| 2 | 1,032.84 | 1,064.23 | 1,096.48 | 1,129.66 | 1,163.81 | 1,198.96 | 1,235.15 | 1,272.40 | 988.29 | 515.68 |
| 3 | 1,702.49 | 1,754.08 | 1,807.14 | 1,861.77 | 1,918.01 | 1,975.91 | 2,035.51 | 2,096.87 | 1,628.68 | 849.82 |
| 4 | 2,406.68 | 2,479.48 | 2,554.41 | 2,631.57 | 2,711.02 | 2,792.82 | 2,877.04 | 2,963.75 | 2,302.00 | 1,201.13 |
| 5 | 3,146.66 | 3,241.72 | 3,339.59 | 3,440.42 | 3,544.24 | 3,651.15 | 3,761.22 | 3,874.58 | 3,009.45 | 1,570.26 |
| 6 | 3,923.70 | 4,042.12 | 4,164.08 | 4,289.74 | 4,419.14 | 4,552.41 | 4,689.65 | 4,830.98 | 3,752.30 | 1,957.86 |
| 7 | 4,209.80 | 4,336.85 | 4,467.70 | 4,602.52 | 4,741.36 | 4,884.35 | 5,031.59 | 4,668.23 | 3,510.89 | 1,379.60 |
| 8 | 4,336.14 | 4,467.01 | 4,601.79 | 4,740.66 | 4,883.67 | 5,030.94 | 4,667.60 | 4,293.33 | 3,101.27 | 700.00 |
| 9 | 4,466.35 | 4,601.14 | 4,739.97 | 4,883.01 | 5,030.31 | 4,667.01 | 4,292.76 | 3,907.25 | 2,679.43 | 0.00 |
| 10 | 4,600.53 | 4,739.37 | 4,882.37 | 5,029.70 | 4,666.43 | 4,292.22 | 3,906.74 | 3,509.67 | 2,038.98 | 0.00 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 11 | 4,738.80 | 4,881.82 | 5,029.11 | 4,665.87 | 4,291.70 | 3,906.26 | 3,509.24 | 3,100.25 | 1,379.37 | 0.00 |
| 12 | 4,881.29 | 5,028.61 | 4,665.33 | 4,291.19 | 3,905.80 | 3,508.84 | 3,099.91 | 2,678.64 | 700.00 | 0.00 |
| 13 | 5,028.13 | 4,664.87 | 4,290.70 | 3,905.35 | 3,508.45 | 3,099.59 | 2,678.39 | 2,038.45 | 0.00 | 0.00 |
| 14 | 4,664.44 | 4,290.30 | 3,904.92 | 3,508.07 | 3,099.29 | 2,678.18 | 2,038.31 | 1,379.10 | 0.00 | 0.00 |
| 15 | 4,289.92 | 3,904.57 | 3,507.70 | 3,098.99 | 2,677.96 | 2,038.20 | 1,379.08 | 700.00 | 0.00 | 0.00 |
| 16 | 3,904.25 | 3,507.42 | 3,098.70 | 2,677.76 | 2,038.09 | 1,379.08 | 700.00 | 0.00 | 0.00 | 0.00 |
| 17 | 3,507.17 | 3,098.50 | 2,677.56 | 2,037.99 | 1,379.08 | 700.00 | 0.00 | 0.00 | 0.00 | 0.00 |
| 18 | 3,098.32 | 2,677.45 | 2,037.88 | 1,379.08 | 700.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| 19 | 2,677.36 | 2,037.87 | 1,379.08 | 700.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| 20 | 2,037.87 | 1,379.08 | 700.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| 21 | 1,379.08 | 700.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| 22 | 700.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |

បញ្ជាក់: នៅខាងឆ្វេងបង្អស់នៃតារាងបង្ហាញអំពី"ការឆ្លងកាត់ប្រចាំឆ្នាំរបស់បណ្ណសន្យារ៉ាប់រង"។ ជួរដេកដំបូងនៃតារាងនេះបង្ហាញអំពី"អាយុនៅពេលអ្នកត្រូវបានធានារ៉ាប់រងធ្វើការស្នើសុំធានារ៉ាប់រង"។



អាគារកាណាឌីយ៉ាជាន់ទី26 CDEF វិថីព្រះអង្គឌួងលេខ315 ក្រុងភ្នំពេញ 26th Floor CDEF Canadia Tower 315 Ang Doung Street Phnom Penh Tel: 023989218